**សមាគមឧកញ៉ាកម្ពុជា**

# របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលការងារ ប្រចាំឆ្នាំ២០២៣



**រៀបរៀងដោយ ៖ អគ្គលេខាធិការដ្ឋាន**

# មាតិកា


១. អំពីសមាគមឧកញ៉ាកម្ពុជា.......................................................................១

២. រចនាសម្ព័ន្ធនៃសមាគមឧកញ៉ាកម្ពុជា...........................................................២

៣. សមាសភាពឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់នៃសមាគមឧកញ៉ាកម្ពុជា.................................៣

៤. រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលនៃសមាគមឧកញ៉ាកម្ពុជា........................................៤

៥. សមាសភាពគណៈកម្មការសមាជិកភាព វិន័យ និងក្រុមសីលធម៌..............................៥

៦. សមាសភាពគណៈកម្មការកិច្ចការច្បាប់ .........................................................៦

៧. សមាសភាពគណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុ.................................................៧

៨. សមាសភាពគណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិ................................៨

៩. សកម្មភាពការងារនិងកិច្ចប្រជុំនានាក្នុងឆ្នាំ២០២៣...............................................៩

១០. សកម្មភាពមនុស្សធម៌ក្នុងឆ្នាំ២០២៣..........................................................៤៥

១១. ផែនការអនុវត្តបន្ត...................................................................................៥០

# អំពីសមាគមឧកញ៉ាកម្ពុជា

សមាគមឧកញ៉ាកម្ពុជា (ស.ឧ.ក.) បានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជានិងត្រូវបានសម្ពោធជាផ្លូវការកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា ព្រមទាំងជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជាផងដែរ។

ជាពិសេស អនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ា បានពីការទទួលស្គាល់សមាគមឧកញ៉ាកម្ពុជាជាផ្លូវការក្នុងនាមជាដៃគូរាជរដ្ឋាភិបាលលើការងារដូចខាងក្រោម៖

- ជាស្ថាប័នតែមួយគត់ដែលតំណាងឱ្យគោរមវន្ត(រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលទទួលបានគោរមងារឧកញ៉ា) ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ជួយរាជរដ្ឋាភិបាលលើការពិនិត្យ និងវាយតម្លៃចំពោះសំណើសុំផ្តល់គោរមងារឧកញ៉ា
- ជួយរាជរដ្ឋាភិបាលលើការប្រមូលវិភាគទានពីគោរមវន្តដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ជួយរាជរដ្ឋាភិបាលលើការធ្វើបច្ចុប្បន្នកម្មបញ្ជីឈ្មោះនិងរៀបចំចាត់ចែងឯកសណ្ឋានផ្លូវការរបស់គោរមវន្តទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា
- ជួយរាជរដ្ឋាភិបាលលើការពិនិត្យសំណើសុំផ្តល់ងារជាកិត្តិយស បុព្វសិទ្ធិនានាឬការតែងតាំងក្នុងមុខងារនានាដល់គោរមវន្ត
- ជាដៃគូរបស់រាជរដ្ឋាភិបាលក្នុងការជំរុញលើកកម្ពស់សេដ្ឋកិច្ចសកម្មភាពពាណិជ្ជកម្មនិងការវិនិយោគព្រមទាំងសកម្មភាពផ្សេងៗទៀតដើម្បីប្រយោជន៍ដល់សង្គមនិងត្រូវបានដាក់ឱ្យស្ថិតនៅក្រោមអភិបាលកិច្ចផ្នែកបច្ចេកទេសរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(ក.អ.ក.)
- អមដំណើរជាមួយនាយករដ្ឋមន្ត្រីក្នុងបេសកកម្មក្នុងនិងក្រៅប្រទេសសំដៅជំរុញលើកកម្ពស់ការធ្វើពាណិជ្ជកម្មនិងវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងឆ្នាំ២០២៣ដែលជាឆ្នាំដំបូងនៃការបង្កើតជាផ្លូវការ សមាគមឧកញ៉ាកម្ពុជាមានសមាជិកចំនួន៣៥១រូបនិងបានកើនដល់ ៣៧២ រូបគិតត្រឹមខែមីនាឆ្នាំ២០២៤នេះ។ សមាជិកទាំងអស់ត្រូវបានបែងចែកជា ទីប្រឹក្សាជាន់ខ្ពស់ សមាជិកស្ថាបនិក សមាជិកសកម្ម និងសមាជិកទ្រទ្រង់ ដែលសុទ្ធតែមានគោរមងារជា អ្នកឧកញ៉ា និង ឧកញ៉ាហើយសុទ្ធសឹងតែជាពាណិជ្ជករដ៏មានសក្តានុពលដែលកំពុងប្រកបរអាជីវកម្មនិងកាន់កាប់ជំនួញពហុវិស័យគ្របដណ្តប់ទូទាំងប្រទេសកម្ពុជាដោយបានបំពេញកាតព្វកិច្ចលើការបង់ពន្ធជូនរដ្ឋការបង្កើតការងាររាប់សិបកន្លែងនៅទូទាំងប្រទេសការកាត់បន្ថយភាពក្រីក្រព្រមទាំងការទាក់ទាញវិនិយោគិនបរទេសដើម្បីរួមចំណែកដល់ការពង្រឹងនិងអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចជាតិស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧ដែលមានសម្តេចមហាបវរធិបតីហ៊ុន ម៉ាណែត ជាប្រមុខដ៏ស្វាហាប់ និងឈ្លាសវៃ។

សមាគមឧកញ៉ាកម្ពុជាមានទស្សនវិស័យរក្សានិងលើកកម្ពស់ឧត្តមភាពដ៏ឧត្តុងឧត្តមនៃគោរមងារឧកញ៉ាតាមរយៈការចូលរួមអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព និងបរិយាបន្ន បង្កើតបាននូវភាពសុខសាន្ត សុខុដុមរមនា និងការរីកចម្រើនខាងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋបានល្អប្រសើរដូចបណ្តាប្រទេសអភិវឌ្ឍន៍នានា។

ជាងនេះទៅទៀត សមាគមមានបេសកកម្មចម្បងៗដូចជា៖

១) ធ្វើជាតំណាងការពារផលប្រយោជន៍ស្របច្បាប់ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់គោរមវន្តដែលជាសមាជិក

២) រួមគ្នាចូលរួមចំណែកក្នុងសកម្មភាពសង្គម និងសប្បុរសធម៌នានា ដើម្បីបង្កើនកិត្យានុភាព ឧត្តមភាព និងគុណធម៌របស់ឧកញ៉ាឱ្យកាន់តែខ្ពង់ខ្ពស់ថែមទៀត

៣) លើកកម្ពស់ការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ព្រះរាជាណាចក្រកម្ពុជា

៤) បង្កើតវេទិកា សិក្ខាសាលា និងកម្មវិធីផ្សេងៗទាំងក្នុងនិងក្រៅប្រទេសដើម្បីលើកកម្ពស់ភាពជាដៃគូនៅក្នុងសកម្មភាពពាណិជ្ជកម្ម និងការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# រចនាសម្ព័ន្ធនៃសមាគមខ្មែរកញ្ញាកម្ពុជា



# សមាសភាពឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់នៃសមាគមឧកញ៉ាកម្ពុជា

## ប្រធានកិត្តិយស



សម្តេចអគ្គមហាសេនាបតីតេជោ
ហ៊ុន សែន

## អនុប្រធានកិត្តិយស



សម្តេចក្រឡាហោម
ស ខេង



សម្តេចពិជ័យសេនា
ទៀ បាញ់



សម្តេចកិត្តិសង្គហបណ្ឌិត
ម៉ែន សំអន



ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត
ចម ប្រសិទ្ធ

## ទីប្រឹក្សាជាន់ខ្ពស់



អ្នកឧកញ៉ា
គិត ម៉េង



អ្នកឧកញ៉ា
ពុង ឃាវសែ



អ្នកឧកញ៉ា
ហុង ពីវ



អ្នកឧកញ៉ា
ឃុន សៀ



អ្នកឧកញ៉ា
ឡាវ ម៉េងឃីន



អ្នកឧកញ៉ា
សុខ គង់



អ្នកឧកញ៉ា
សំ អាង



អ្នកឧកញ៉ា
ឈុន អ៊ូន

# គណៈកម្មការសមាជិកភាព វិន័យ និងក្រមសីលធម៌



អ្នកឧកញ៉ា លី ហួរ
ប្រធាន



អ្នកឧកញ៉ា ឡាវ គាង
អនុប្រធាន



អ្នកឧកញ៉ា លាង ឃុន
អនុប្រធាន



អ្នកឧកញ៉ា តែ អ៊ីវ៉ៃ
អនុប្រធាន



អ្នកឧកញ៉ា ទីវ ម៉េងហ៊ុយ
សមាជិក



អ្នកឧកញ៉ា ជៀម ផែន
សមាជិក



អ្នកឧកញ៉ា ទី ពិសិដ្ឋ
សមាជិក



អ្នកឧកញ៉ា ហ៊ុន ឡាក់
សមាជិក



អ្នកឧកញ៉ា ហ៊ី ឆាវី
សមាជិក

# គណៈកម្មការកិច្ចការច្បាប់



**អ្នកឧកញ៉ា លាង ម៉េង**

ប្រធាន



**អ្នកឧកញ៉ា ហ៊ី ឆាវី**

អនុប្រធាន



**អ្នកឧកញ៉ា ហេង ឡុង**

អនុប្រធាន



**អ្នកឧកញ៉ា គង់ សាង**

អនុប្រធាន



**អ្នកឧកញ៉ា តេង ហឿង**

សមាជិក



**អ្នកឧកញ៉ា ឡាវ ភាង**

សមាជិក



**អ្នកឧកញ៉ា ហ៊ុន ឡាក់**

សមាជិក



**អ្នកឧកញ៉ា លី ម៉ោយុ**

សមាជិក

# គណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុ



អ្នកឧកញ៉ា ផៃ ហុកឈួន
ប្រធាន



អ្នកឧកញ៉ា ហេង លី
អនុប្រធាន



អ្នកឧកញ៉ាបណ្ឌិត ថិញ ហ៊ួរ
អនុប្រធាន



អ្នកឧកញ៉ា អ៊ាន សេឡែន
អនុប្រធាន



អ្នកឧកញ៉ា សុខ ឆេង
អនុប្រធាន



អ្នកឧកញ៉ា ផាត់ ប៊ុន
សមាជិក



អ្នកឧកញ៉ា អ៊ុន ក្ងូត
សមាជិក



អ្នកឧកញ៉ា លី សាំងឡេង
សមាជិក



អ្នកឧកញ៉ា តេង ហឿង
សមាជិក



អ្នកឧកញ៉ា ហ៊ុន ឡាក់
សមាជិក

# គណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិ



អ្នកឧកញ៉ា សៀ ឫទ្ធី
ប្រធាន



អ្នកឧកញ៉ា ភុក អាន
អនុប្រធាន



អ្នកឧកញ៉ា ថៃ ជាហួត
អនុប្រធាន



អ្នកឧកញ៉ា ហុង ស៊ួន ស៊ីគង់ធ្វីវ
អនុប្រធាន



អ្នកឧកញ៉ា ហាន់ ឃាង
អនុប្រធាន



អ្នកឧកញ៉ា លី ហុង
សមាជិក



អ្នកឧកញ៉ា ប៊ុន ហៃ
សមាជិក



អ្នកឧកញ៉ា ស៊ី ហ៊ុហ៊ុយ
សមាជិក



អ្នកឧកញ៉ា អ៊ាន អេឡែន
សមាជិក



អ្នកឧកញ៉ា ជា ធ្វី
សមាជិក



អ្នកឧកញ៉ា តេង ហឿង
សមាជិក

# សកម្មភាពការងារនិងកិច្ចប្រជុំនានាក្នុងឆ្នាំ២០២៣

អនុលោម តាមទស្សនវិស័យ និងបេសកកម្មរបស់ខ្លួន នៅក្នុងឆ្នាំ២០២៣កន្លងមក ក្រុមប្រឹក្សាភិបាលនៃសមាគមឧកញ៉ាកម្ពុជាក្រោមការដឹកនាំរបស់ អ្នកឧកញ៉ា លី យ៉ុងផាត់ បានបំពេញការងារយ៉ាងសកម្មបំផុតដោយសហការយ៉ាងជិតស្និទ្ធជាមួយអ្នកឧកញ៉ាជាប្រធាន អនុប្រធាន និងជាសមាជិកគណៈកម្មការជំនាញទាំង ៤ ដើម្បីជំរុញសកម្មភាពរបស់សមាគមបោះជំហានឆ្ពោះទៅមុខជាលំដាប់។ ជាក់ស្តែង អនុលោមតាមលក្ខន្តិកៈរបស់សមាគម ក្រុមប្រឹក្សាភិបាលបានរៀបចំកិច្ចប្រជុំសាមញ្ញចំនួន ៣លើក, កិច្ចប្រជុំវិសាមញ្ញចំនួន ៦លើក និងកិច្ចប្រជុំគណៈកម្មការជំនាញចំនួន ៦លើកផងដែរ។ រាល់កិច្ចប្រជុំទាំងអស់បានប្រព្រឹត្តទៅដោយការពិភាក្សា និងលទ្ធផលជាផ្លែផ្កាដើម្បីបង្កើតនូវយន្តការនានាដើម្បីធានាបាននូវការប្រព្រឹត្តទៅរបស់សមាគម ទាំងសកម្មភាពការងារប្រចាំថ្ងៃ សកម្មភាពមនុស្សធម៌ ការចូលរួមជាមួយរាជរដ្ឋាភិបាលលើសកម្មភាពជំរុញកំណើនសេដ្ឋកិច្ចជាតិ និងទាក់ទាញវិនិយោគពីក្រៅប្រទេសរួមទាំងការដោះស្រាយបាននូវបញ្ហាប្រឈមរបស់សមាជិកសំដៅលើកតម្កើងកិត្តិនាមរបស់គោមរមវន្តនៅក្នុងសង្គមស័ក្តិសមទៅនឹងគោរមងារជា អ្នកឧកញ៉ា និង ឧកញ៉ា ដែលទទួលបាននូវការប្រោសព្រះរាជទានដ៏ឧត្តុង្គឧត្តមពីអង្គព្រះមហាក្សត្រ។










## កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង

# កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី២ អាណត្តិទី១ នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣



















# កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៣ អាណត្តិទី១
# នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣















# ពិធីចូលជួបសម្តែងការគួរសមចំពោះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា



នាថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ ២០២៣ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូដែលជាសមាជិកស្ថាបនិកនិងជាក្រុមប្រឹក្សា ភិបាល ចូលជួបសម្តែងការគួរសមចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងជាប្រធានកិត្តិយសនៃសមាគមឧកញ៉ាកម្ពុជា នាភូមិគ្រឹះរបស់សម្តេច ក្នុងក្រុងតាខ្មៅ។ អ្នកឧកញ៉ា លី យ៉ុងផាត់ បានសម្តែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះសម្តេចដែលបានអនុញ្ញាតអោយគណៈប្រតិភូសមាគមបានចូលជួបសម្តែងការគួរសមនិងជម្រាបជូនសម្តេចតេជោអំពីការបង្កើតឡើងជាផ្លូវការនូវសមាគមឧកញ៉ាកម្ពុជា ទស្សនវិស័យ និងបេសកកម្មរបស់សមាគម និងធ្វើការណែនាំអំពីសមាជិកស្ថាបនិកនិងជាក្រុមប្រឹក្សាភិបាលប្រធានគណៈកម្មការជំនាញទាំង៤និងអគ្គលេខាធិការ១រូបដែលដឹកនាំប្រតិបត្តិការងារប្រចាំថ្ងៃ របស់សមាគម។ អ្នកឧកញ៉ា លី យ៉ុងផាត់ និងសមាជិកក៏បានស្នើសុំនូវមតិណែនាំបន្ថែមពីសំណាក់សម្តេចតេជោក្នុងនាមសម្តេចជាប្រធានកិត្តិយសសម្រាប់កិច្ចដំណើរការរបស់សមាគមឆ្ពោះទៅសម្រេចចក្ខុវិស័យដែលបានកំណត់។

ឆ្លៀតឱកាសនោះផងដែរ អ្នកឧកញ៉ា លី យ៉ុងផាត់ និងសមាជិកទាំងអស់បានគោរពថ្លែងអំណរគុណចំពោះ សម្តេចដែលបានយល់ព្រមធ្វើជាប្រធានកិត្តិយនៃសមាគមឧកញ៉ាកម្ពុជា និងក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរដែលនឹងមកដល់ក្នុងពេលដ៏ខ្លីខាងមុខនេះ បួងសួងគោរពជូនពរជ័យគ្រប់ប្រការជូន **សម្តេច** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង បុត្រាបុត្រី បុត្រប្រសារ ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ បានប្រកបនូវពុទ្ធពរទាំងបួន ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍។

ជាការឆ្លើយតប សម្តេចតេជោ បានកោតសរសើរ និងវាយតម្លៃខ្ពស់អំពីការបង្កើតសមាគមឧកញ៉ាកម្ពុជា ដែលជាការរួមគ្នាប្រមូលកំលាំងធនធានប្រាជ្ញានិងបទពិសោធន៍ចូលរួមជួយអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជានិងការជំរុញការវិនិយោគក្នុងប្រទេសបង្កើតការងារជូនប្រជាជន **សម្តេចតេជោ** បានណែនាំឱ្យពង្រឹងលេខាធិការដ្ឋានសម្រាប់ប្រត្តិបត្តិកិច្ចការសមាគមធ្វើយ៉ាងណាជួយសមាគមឱ្យមាននិរន្តរភាព។ សម្តេចតេជោ ពិតជាត្រេកអរដែលឧកញ៉ាបានរួមគ្នាបង្កើតសមាគមឧកញ៉ាកម្ពុជានេះឡើងដើម្បីចូលរួមចំណែកកិច្ចការងារសង្គមនិងការងារមនុស្សធម៌។














# ការចុះអនុស្សារណៈយោគយល់គ្នា ស្ដីពីភាពជាដៃគូក្នុងការជំរុញ និងលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម និងការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃព្រហស្បតិ៍ ៦កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ សមាគមឧកញ៉ាកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្ដីពីភាពជាដៃគូក្នុងការជំរុញ និងលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម និងការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) និង សមាគមឧកញ៉ាកម្ពុជា (ស.ឧ.ក.)។ អនុស្សារណៈនេះមាន ៧មាត្រាអមដោយផែនការ៣ឆ្នាំរំកិលអំពីការកំណត់សូចនាករសមិទ្ធកម្មនិងគោលដៅនៃកម្មវិធីនិងអនុកម្មវិធីនានា ដោយមានសកម្មភាពសរុបចំនួន ១២។













CDC


CDC






# ពិធីប្រកាសជាផ្លូវការសមាគមឧកញ៉ាកម្ពុជា និងពិសាអាហារសាមគ្គី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាថ្ងៃសៅរ៍ ៧រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ សមាគមឧកញ៉ាកម្ពុជាបានរៀបចំពិធីប្រកាសជាផ្លូវការនិងពិសាអាហារសាមគ្គីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ពិធីនេះប្រារព្ធធ្វើឡើងដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនិងអ្នកមានគោរមងារជាឧកញ៉ានៅទូទាំងប្រទេសកម្ពុជា ព្រមទាំងអ្នកជំនួញ ពាណិជ្ជករធំៗ និងតំណាងពីវិស័យឯកជនសំខាន់ៗមួយចំនួនទៀត។ ក្នុងឱកាសប្រកបដោយមហាកិត្តិយសនេះសម្តេចតេជោបានមានប្រសាសន៍ថា៖«សមាគមឧកញ៉ាកម្ពុជាគឺតំណាងឱ្យសំឡេងរួមសកម្មភាពសប្បុរសធម៌រួម និងគុណតម្លៃដ៏ឧត្តុង្គឧត្តមនៃគោរមងារឧកញ៉ាដែលជាសមាជិកទាំងអស់។»

ជាមួយគ្នានេះសម្តេចក៏បានជំរុញទៅដល់ឧកញ៉ាទាំងអស់ចូលរួមជាមួយនឹងរាជរដ្ឋាភិបាលក្នុងការរួមចំណែកអភិវឌ្ឍន៍សង្គមជាតិពិសេសក្នុងបេសកកម្មកាត់បន្ថយភាពក្រីក្រទ្រទ្រង់ខឿនសេដ្ឋកិច្ចជាតិការពារប្រយោជន៍ជាតិមាតុភូមិតាមរយៈការបង្កើតធុរកិច្ចបន្ថែមឬទាក់ទាញធុរកិច្ចឬសមាគមវិនិយោគបរទេសធំៗឱ្យមកបណ្តាក់ទុនវិនិយោគនៅកម្ពុជាឲ្យបានកាន់តែច្រើនបន្ថែមទៀត។សម្តេចតេជោសង្ឃឹមថាសមាគមឧកញ៉ាកម្ពុជានិងក្លាយជាថ្នាលសាបព្រួស និងជាមូលដ្ឋានគ្រឹះនៃបណ្តាទំនាក់ទំនងសហការដៃគូធុរកិច្ចនិងវិនិយោគធំៗនៅកម្ពុជាព្រមទាំងជាដៃគូមិនអាចខ្វះបានរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតតួនាទីរបស់កម្ពុជាឲ្យកាន់តែខ្ពស់លើឆាកអន្តរជាតិ។




















































## វេទិកាធុរកិច្ចឆ្នាំ២០២៣ និងពិធីពិសារអាហារសាមគ្គី រៀបចំដោយសមាគមឧកញ៉ាកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ឈរលើស្មារតីនៃកិច្ចសហប្រតិបត្តិការក្នុងការជំរុញសកម្មភាពពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា នាថ្ងៃព្រហស្បតិ៍ ៩រោច ខែទុតិយសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ សមាគមឧកញ៉ាកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសហការរៀបចំ «វេទិកាធុរកិច្ចឆ្នាំ២០២៣ និងពិធីពិសាអាហារសាមគ្គី» ដោយមានការចូលរួមពីភ្ញៀវកិត្តិយសចំនួន ៤០០រូប និងមានរៀបចំជាការពិភាក្សាជាមួយវាគ្មិនអំពីប្រធានបទផ្សេងៗជាច្រើនផ្សេងៗគ្នា ដែលមានវាគ្មិនជំនាញៗដូចជា៖ ឯកឧត្តម ជា វុទ្ធី អគ្គលេខាធិការងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធ្វើការបង្ហាញពាក់ព័ន្ធបទប្បញ្ញត្តិ ច្បាប់ និងវិនិយោគ, អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាអគ្គនាយកក្រុមហ៊ុន World Bridge Group បង្ហាញពាក់ព័ន្ធវិស័យភស្តុភារកម្ម និងដឹកជញ្ជូន, អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា និងជាប្រធានក្រុមហ៊ុន Tropicam Group បង្ហាញពាក់ព័ន្ធកសិ-ផលិតកម្ម, អ្នកឧកញ៉ា គង់ សាង ប្រធានសមាគមវាយនភណ្ឌសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា បង្ហាញពាក់ព័ន្ធវិស័យវាយនភណ្ឌកាត់ដេរ ស្បែកជើង និងកាបូប, អ្នកឧកញ៉ា លាង ម៉េង អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាអគ្គនាយកក្រុមហ៊ុន Chip Mong Group បង្ហាញពាក់ព័ន្ធវិស័យអចលនទ្រព្យ និងបដិសណ្ឋារកិច្ច, ឧកញ៉ា វ៉ាន់ ឆារស័ជួន អភិបាលក្រុមហ៊ុនកាណាឌីយ៉ាគ្រុប ប្រធានស្តីទីសមាគមអ្នកសាង់សង់កម្ពុជា បង្ហាញពាក់ព័ន្ធវិស័យសំណង់ និងធនាគារ, ជំទាវឧកញ៉ា កែវ មុំ ស្ថាបនិកក្រុមហ៊ុននំស្រួយលីលី បង្ហាញអំពីប្រធានបទពាក់ព័ន្ធកម្មន្តសាលនិងសហគ្រាសធុនតូចនិងមធ្យមនិងបណ្ឌិតឆេងគីមឡុងសេដ្ឋកិច្ចវិទូផ្នែកសេដ្ឋកិច្ចនៃវិទ្យាស្ថានចក្ខុវិស័យអាស៊ីបង្ហាញពាក់ព័ន្ធសេដ្ឋកិច្ចកម្ពុជា និងនៅក្នុងតំបន់។















& Gala Dinner 2023
arden City Hotel Phnom Penh August 11, 2023




Cambodia Business Forum
& Gala Dinner 2023


& Gala Dinner 2023
Garden City Hotel Phnom Penh August 11, 2023









## ពិធីគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា ប៊ុន ស៊ី ដែលត្រូវជាម្តាយបង្កើត អ្នកឧកញ៉ា កុក អាន អនុប្រធានសមាគមឧកញ៉ាកម្ពុជា

នៅថ្ងៃអង្គារ ៤រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ អ្នកឧកញ៉ា លី ហួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា ប៊ុន ស៊ី ត្រូវជាម្តាយបង្កើត អ្នកឧកញ៉ា កុក អាន ដែលបានទទួលមរណភាពនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣ ក្នុងជន្មាយុ ៨៦ឆ្នាំដោយជរាពាធ។

ក្នុងវេលាដ៏ក្រៀមក្រំនេះអ្នកឧកញ៉ានិងឧកញ៉ាជាអនុប្រធានក៏ដូចជាសមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមឧកញ៉ាកម្ពុជា បានចូលរួមរំលែកទុក្ខប្រកបដោយក្តីអាឡោះអាល័យជាមួយគ្រួសារសពចំពោះការបាត់បង់ម្តាយបង្កើត ម្តាយក្មេក ជីដូន ជីដូនទួត ជាទីគោរពស្រលាញ់និងពោរពេញដោយព្រហ្មវិហារធម៌។









ថ្ងៃទី០១-០៥ ខែតុលា ឆ្នាំ២០២៣











## ថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជាអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពីគោលនយោបាយ អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨

អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការនៃសមាគមឧកញ៉ាកម្ពុជា និងជាតំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ បាន អញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី «គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨» ដែលរៀបចំឡើងដោយគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ) នៅ សណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ នាថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។

















## ថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជា អញ្ជើញចូលរួមក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ យុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨

នៅថ្ងៃអង្គារ ១១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ថ្នាក់ដឹកនាំជាអនុប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមឧកញ៉ាកម្ពុជារួមមាន អ្នកឧកញ៉ា លី ហួរ, អ្នកឧកញ៉ា លាង ឃុន, អ្នកឧកញ៉ា សៀ ឬទ្ធី, អ្នកឧកញ៉ា វិញ ហ៊ួរ, អ្នកឧកញ៉ា ហ៊ុន ឡាក់ និង អ្នកឧកញ៉ា ហ៊ី បារី បានអញ្ជើញចូលរួមក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ «យុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដែលបានប្រារព្ធឡើងនៅសណ្ឋាគារសុខាភ្នំពេញ និងរ៉េស៊ីដង់។


















## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សព្វព្រះរាជហឫទ័យឡាយព្រះហស្តលេខាប្រកាសឱ្យប្រើព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ា

នាថ្ងៃពុធ ១២រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតបានសព្វព្រះរាជហឫទ័យឡាយព្រះហស្តលេខាប្រកាសឱ្យប្រើព្រះរាជក្រឹត្យលេខនស/រកត/១០២៣/២២៥០ចុះថ្ងៃទី១១ខែតុលាឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ា តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ព្រះរាជក្រឹត្យនេះ មាន១១ជំពូក និង ២៦មាត្រាដោយបានកំណត់អំពីគោលការណ៍ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការផ្តល់គោរមងារឧកញ៉ា ជាការលើកទឹកចិត្តដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលមានគុណបំណាច់ក្នុងការចូលរួមអភិវឌ្ឍ និងកសាងជាតិ ព្រមទាំងការគ្រប់គ្រងនិងការបញ្ចប់គោរមងារឧកញ៉ាដើម្បីធានាបាននូវសេចក្តីថ្លៃថ្នូរ ទំនៀមទម្លាប់ ប្រពៃណីល្អ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

ព្រះរាជក្រឹត្យដ៏មានសារៈសំខាន់នេះដែរក៏បានបញ្ញត្តិអំពីការទទួលស្គាល់នូវតួនាទីរបស់សមាគមឧកញ៉ាកម្ពុជាក៏ដូចជាអត្ថន័យនៃនិមិត្តសញ្ញារបស់សមាគមព្រមទាំងឯកសណ្ឋានផ្លូវការរបស់គោរមវន្តដែលត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ដោយសមាគមឧកញ៉ាកម្ពុជាផងដែរ។






































## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត បានចេញសេចក្តីសម្រេចតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងពិនិត្យ និងវាយតម្លៃលើសំណើសុំគោរមងារ និងការបញ្ចប់គោរមងារឧកញ៉ា (គ.ព.វ.គ)

នាពុធ ១០រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ប្រមុខរាជរដ្ឋាភិបាល **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានចេញសេចក្តីសម្រេចតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងពិនិត្យ និងវាយតម្លៃលើសំណើសុំគោរមងារ និងការបញ្ចប់គោរមងារឧកញ៉ា (**គ.ព.វ.គ**) ដែលមានសមាសភាពដូចជា៖

| | |
|---|---|
| ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ឯកឧត្តម ប៊ុន ហុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ឯកឧត្តម ឈួន ឆាម រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធានប្រចាំការ |
| ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ឯកឧត្តម តាន់ហ៊ាង ដាវ័ណ្ណ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ឯកឧត្តម សោម សុគន្ធ រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ឯកឧត្តម សេង សុមុនី រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| អ្នកឧកញ៉ា លី ហួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជា | សមាជិក |
| អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា | សមាជិក |
| ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានឥស្សរិយយសនិងគោមរងារ | លេខាធិការ |




















Office of the Council of Ministers

ថ្នាក់ដឹកនាំ ក៏ដូចជាសមាជិកចំនួន ៨០រូបនៃសមាគមឧកញ៉ាកម្ពុជានឹងអញ្ជើញចូលរួមវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ទៅតាមការរៀបចំនិងសម្របសម្រួលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលកម្មវិធីនេះនឹងប្រព្រឹត្តទៅនៅថ្ងៃចន្ទ ១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នាវិមានសន្តិភាពក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ វេទិការវាងរាជរដ្ឋាភិបាល និងវិស័យឯកជននេះ ត្រូវបានទទួលស្គាល់ថាជា វេទិកាថ្នាក់ជាតិ និងជាយន្តការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជជែកសន្ទនាជាមួយផ្នែកឯកជន ដើម្បីស្វែងយល់អំពីសំណូមពរ និងបញ្ហាប្រឈមនានាដែលវិស័យឯកជនបានជួបប្រទះក្នុងកិច្ចការអនុវត្តអាជីវកម្មរបស់ខ្លួននៅកម្ពុជា ជាពិសេសត្រូវបានចាត់ទុកថាជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបើកទូលាយដោយរាល់សេចក្តីសម្រេចនានានៃវេទិកានេះនឹងមានអនុភាពជាសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីផងដែរ។

























# កិច្ចប្រជុំក្រុមការងារអមដំណើរទស្សនកិច្ចផ្លូវការរបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

នៅព្រឹកថ្ងៃសុក្រ ៤រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា និងលោក យឿម ប៉ូរ៉ាន ជាអគ្គលេខាធិការរងបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាអំពីការរៀបចំការងារដើម្បីអមដំណើរទស្សនកិច្ចផ្លូវការរបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជានៅសាធារណរដ្ឋសង្គមនិយមវៀតណាមក៏ដូចជាចូលរួមវេទិកាវិនិយោគ និងពាណិជ្ជកម្មកម្ពុជា-វៀតណាម ឆ្នាំ២០២៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០២៣ នៅរដ្ឋធានីហាណូយ។ កិច្ចប្រជុំនេះបានប្រព្រឹត្តិទៅនៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្រោមការដឹកនាំរបស់ឯកឧត្តម សួន សុផល អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា (គ.វ.ក.) ដោយការអញ្ជើញចូលរួមពីក្រុមការងារសភាពាណិជ្ជកម្មកម្ពុជា និងតំណាងក្រសួងពាណិជ្ជកម្មផងដែរ។













# ថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាបានអញ្ជើញចូលរួមជាភ្ញៀវកត្តិយស នៃពិធី អបអរសាទរខួបគម្រប់ ៩ឆ្នាំរបស់មន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ

ថ្នាក់ដឹកនាំក៏ដូចជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជាបានអញ្ជើញចូលរួមជាភ្ញៀវកត្តិយស នៃពិធីអបអរសាទរខួបគម្រប់ ៩ឆ្នាំរបស់មន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញដែលបានប្រព្រឹត្តទៅក្រោម អធិបតីភាពរបស់ ឯកឧត្តម ស៊ិក ប៊ុណ្ណា រដ្ឋលេខាធិការក្រសួងសុខាភិបាល និងវត្តមានអ្នក ឧកញ៉ា លី យ៉ុងផាត់ ប្រធានក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យរ៉ូយ៉ាល់ ភ្នំពេញ។ កម្មវិធីនេះបានប្រារព្ធឡើង នៅ សណ្ឋាគារ ហ្គាឌិន ស៊ីធី នាថ្ងៃទីសៅរ៍ ៥រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៣។






















## ថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជាអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយលោក Marwan Al Marri នាយកប្រចាំតំបន់អាស៊ី នៃសភាពាណិជ្ជកម្មឌូបៃ

នៅថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២ អ្នកឧកញ៉ា លី ហួរ និង អ្នកឧកញ៉ា សៀ ឫទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាការងាររវាង ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាមួយ លោក Marwan Al Marri នាយកប្រចាំតំបន់អាស៊ី នៃសភាពាណិជ្ជកម្មឌូបៃ។

អ្នកឧកញ៉ា សៀ ឫទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា បានលើកឡើងថា សមាគមឧកញ៉ាកម្ពុជាគឺជាស្ថាប័នឯកជនដែលមានសក្តានុពលក្នុងការចាប់ដៃគូវិនិយោគជាមួយវិនិយោគិនក្រៅប្រទេសដោយហេតុថា សមាជិកទាំង ៣៥០រូបសុទ្ធតែជាពាណិជ្ជករដែលកំពុងគ្រប់គ្រងអាជីវកម្មជាច្រើនគ្រប់ដណ្តប់ស្ទើរគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជាហើយកំពុងតែសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងការជំរុញសកម្មភាពពាណិជ្ជកម្មនិងវិនិយោគនៅកម្ពុជា។អ្នកឧកញ៉ាបានបញ្ជាក់ដែរថាកម្ពុជាមានផលិតផលជាច្រើនដើម្បីបំពេញតម្រូវការរបស់ភាគីឌូបៃដូចជាស្វាយចន្ទីម្រេចកៅស៊ូនិងផលិតផលជាច្រើនផ្សេងទៀត ហេតុនេះ អ្នកឧកញ៉ា មានក្តីរំពឹងថា ភាគីទាំងពីរនឹងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មកាន់តែខ្លាំងថែមទៀតដូចជាការបើកការហោះហើរដោយត្រង់រវាងឌូបៃ-កម្ពុជា ការបញ្ជាទិញផលិតផលពីកម្ពុជា និងការគៀងគរវិនិយោគិនឌូបៃមកកម្ពុជាជាដើម។អ្នកឧកញ៉ាបានសង្កត់ធ្ងន់ដែរថាបើប្រៀបធៀបជាមួយបណ្តាប្រទេសជិតខាងដែលឌូបៃកំពុងវិនិយោគដូចជាប្រទេសថៃជាដើមនោះ កម្ពុជាក៏មានលក្ខណៈពិសេសនិងអំណោយផលដូចគ្នា ហេតុនេះ អ្នកឧកញ៉ាបានស្នើដល់ សភាពាណិជ្ជកម្មឌូបៃ ជំរុញក៏ដូចជាលើកទឹកចិត្តវិនិយោគិនរបស់ខ្លួនមកកាន់ប្រទេសកម្ពុជាវិញ ជាពិសេសការកសាងកាលានុវត្តភាពក្នុងការរៀបចំយន្តការពាណិជ្ជកម្មដោយនាំចេញផលិតផលពីកម្ពុជាទៅកាន់ឌូបៃហើយបន្តចែកចាយទៅកាន់ទ្វីបអឺរ៉ុប ឬតំបន់ផ្សេងៗទៀតព្រោះឌូបៃគឺជាទីផ្សារចែកចាយផលិតផលរបស់អាស៊ីទៅកាន់ពិភពលោកទាំងមូល។














ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia



# អ្នកឧកញ៉ា លី យ៉ុងផាត់ និងថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជាចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ សីលវិសុទ្ធសិរីចេនាអគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ នាង ហ៊ុច

នាថ្ងៃអង្គារ ១៥រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំក្រុមប្រឹក្សាភិបាល និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ និងជូនលិខិតរំលែកមរណទុក្ខ សីលវិសុទ្ធសិរីរចនាអគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ នាង ហ៊ុច ដែលត្រូវជាម្តាយក្មេករបស់ អ្នកឧកញ៉ា សំ អាង ជាទីប្រឹក្សាជាន់ខ្ពស់សមាគមឧកញ៉ាកម្ពុជា និងត្រូវជាម្តាយក្មេករបស់ អ្នកឧកញ៉ា ឡាយ ប៊ុនប៉ា ជាសមាជិកសកម្ម ព្រមទាំងត្រូវជាជីដូនរបស់ ឧកញ៉ា ឡាយ ប៊ុណ្ណាវឌ្ឍន៍ ជាសមាជិកទ្រទ្រង់សមាគមឧកញ៉ាកម្ពុជាផងដែរ។














# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមដំណើរសម្ដេចមហាបវរធិបតីក្នុងកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-ជប៉ុន

គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាដឹកនាំដោយ អ្នកឧកញ៉ា សៀ ឫទ្ធី តំណាង អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមកម្ពុជា រួមជាមួយ អ្នកឧកញ៉ា ហាន់ ឃាង ជំទាវអ្នកឧកញ៉ា អ៊ាន អេឡែន និង អ្នកឧកញ៉ា ហ៊ុន ឡាក់បានចូលរួមអមដំណើរសម្ដេចមហាបវរធិបតីក្នុងកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន - ជប៉ុនចាប់ពីថ្ងៃទី១៥-១៩ ខែធ្នូ ឆ្នាំ២០២៣។ ក្នុងដំណើរទស្សនកិច្ចនេះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាបានអញ្ជើញទស្សនកិច្ចទីស្នាក់ការកណ្ដាលនៃសភាពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន (Japan Chamber Commerce and Industry-JCCI) នៅទីក្រុងតូក្យូ និងជំនួបធុរកិច្ចជាមួយក្រុមហ៊ុនធំៗចំនួន ៧ ។នេះជាជំនួបធុរកិច្ចលើកដំបូងរវាង ស.ឧ.ក – JCCI ដោយមានតំណាងជាអនុប្រធាននៃ ស.ឧ.ក និងថ្នាក់ដឹកនាំក៏ដូចជាតំណាងក្រុមហ៊ុនធំៗចំនួន៧របស់ជប៉ុនបានចូលរួមជជែកពិភាក្សានិងផ្លាស់ប្ដូរបទពិសោធន៍ថែមទាំងបានសិក្សាស្វែងយល់អំពីសមាគមឧកញ៉ាកម្ពុជាក្នុងគោលបំណងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្នានៅពេលអនាគតខណៈដែលសភាពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន (JCCI) ដែលជាស្ថាប័នឯកជនមានក្រុមហ៊ុនជាង ១លាន៥សែន ជាសមាជិក។ ក្នុងឱកាសនោះដែរ អ្នកឧកញ៉ា សៀ ឫទ្ធី បានជម្រាបជូនភាគីជប៉ុនថា សមាគមឧកញ៉ាកម្ពុជា ត្រូវបានបង្កើតឡើងជាមួយនឹងទស្សនវិស័យក៏ដូចជាបេសកកម្មចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការកសាង និងអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចជាតិប្រកបដោយចីរភាពនិងរួមចំណែកលើសកម្មភាពមនុស្សធម៌សង្គមកិច្ចដើម្បីភាពរីកចម្រើនរបស់ប្រជាជនកម្ពុជា












国歌斉唱 /
The National Anthem











## ថ្នាក់ដឹកនាំនិងសមាជិកសមាគមឧកញ៉ាកម្ពុជាចូលរួមពិធីអបអរសាទរខួបទី២៥ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជាតាមរយៈនយោបាយឈ្នះ ឈ្នះ និងខួបទី៥ឆ្នាំ នៃវិមានឈ្នះ ឈ្នះ

ថ្ងៃសុក្រ ២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ថ្នាក់ដឹកនាំក៏ដូចជាសមាជិក-សមាជិកានៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមពិធីអបអរសាទរខួបទី២៥ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជាតាមរយៈនយោបាយឈ្នះ ឈ្នះ និងខួបទី៥ឆ្នាំនៃវិមានឈ្នះ ឈ្នះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។











## ១ សកម្មភាពមនុស្សធម៌ជាមួយសាលារាជធានីភ្នំពេញដើម្បីផ្តល់នូវអំណោយដល់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងតំបន់បិទខ្ទប់អំឡុងពេលរាលដាលនៃវីរុសកូវីដ១៩

ខណៈពេលដែលវីរុសកូវីដ ១៩ បានរីករាលដាលជាខ្លាំង និងបានបង្កផលវិបាកយ៉ាងខ្លាំងដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសក្នុងអំឡុងពេលបិទខ្ទប់នោះ អ្នកឧកញ៉ា លី យ៉ុងផាត់ រួមជាមួយថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជាក៏ដូចជាសមាជិកនិងសប្បុរសជននានាបានចូលរួមបរិច្ចាគថវិកាជាមួយសាលារាជធានីភ្នំពេញដើម្បីផ្តល់នូវអំណោយជាគ្រឿងឧបភោគ បរិភោគ អាល់កុល ម៉ាស់ ព្រមទាំងសម្ភារៈផ្សេងៗទៀតដល់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងតំបន់បិទខ្ទប់នៅរាជធានីភ្នំពេញសរុបជាថវិកាចំនួន ចំនួន ១,១៤៩,២៩៣ ដុល្លារអាម៉េរិក។

## ២. ការចូលរួមបរិច្ចាគថវិកាសម្រាប់គាំទ្រដល់សកម្មភាពបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះផ្សេងទៀតនៅកម្ពុជា

នៅថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ តបតាមការអំពាវនាវដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាថ្នាក់ដឹកនាំក៏ដូចជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជាចំនួន៥៧រូបបានចូលរួមបរិច្ចាគនិងមានទឹកប្រាក់សរុបចំនួន ២,៧៤២,៩១០ ដុល្លារអាម៉េរិកសម្រាប់គាំទ្រដល់សកម្មភាពបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះផ្សេងទៀតនៅកម្ពុជា។

## ៣. ការថ្វាយដង្វាយជាថវិកាថ្វាយ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ប៊ូ គ្រី ដើម្បីចូលរួមអភិវឌ្ឍន៍ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា

នាថ្ងៃព្រហស្បតិ៍ ១០រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដំណើរដោយ អ្នកឧកញ៉ា និងឧកញ៉ាជាច្រើនរូបទៀតបាននាំនូវបច្ច័យសរុបចំនួន ២.៤២១.៧២២ ដុល្លារអាម៉េរិកថ្វាយ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិតប៊ូគ្រីសម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជាដើម្បីចូលរួមអភិវឌ្ឍន៍ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា។ ថវិកានេះមានការចូលរួមពីសមាជិកចំនួន ៩០រូប។

## ៤. សកម្មភាពមនុស្សធម៌ជាមួយសមាគមយុវជនគ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (TYDA) ដើម្បីរៀបចំមន្ទីរពេទ្យ ហ្លួងម៉ែ

ចូលរួមកម្មវិធីខួប១០ឆ្នាំនៃសមាគមយុវជនគ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (TYDA) ព្រមទាំងបរិច្ចាគថវិកាដើម្បីរៀបចំមន្ទីរពេទ្យហ្លួងម៉ែសរុបចំនួន១,១០៤,៨៩៥ដុល្លារអាម៉េរិក។សូមបញ្ជាក់ថាយោងតាមចំណាររបស់សម្តេចតេជោ ហ៊ុន សែន កាលពីថ្ងៃទី ២៨ ខែមីនា កន្លងទៅនេះ មន្ទីរពេទ្យស្រ្តីនគរទេព និងត្រូវប្តូរឈ្មោះទៅជាមន្ទីរពេទ្យហ្លួងម៉ែ ដើម្បីថ្វាយព្រះបរមរាជកិត្តិយសចំពោះព្រះរាជកិច្ចដឹកនាំប្រកបដោយទសពិធរាជធម៌តាមព្រះរាជលំអានព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យជាតិខ្មែរ ព្រះបរមកោដ្ឋជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់។ក្រោយមកមន្ទីរពេទ្យនេះត្រូវបានប្រើប្រាស់ដើម្បីព្យាបាលអ្នកជំងឺកូវីដ១៩និងបន្ទាប់មកទៀតបានប្តូរមកព្យាបាលជំងឺទូទៅដើម្បីបម្រើសេវាសុខាភិបាល ដូចជាការព្យាបាល និងថែទាំដល់ពលរដ្ឋខ្មែរទូទៅ។

# ថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជាចូលរួមបុណ្យផ្កាប្រាក់សាមគ្គីដែលផ្តួចផ្តើមដោយ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស និង ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ

នៅថ្ងៃព្រហស្បតិ៍ ១២កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ ថ្នាក់ដឹកនាំនៃសមាគមឧកញ៉ាកម្ពុជាបាននាំយកបច្ច័យចូលរួមបុណ្យផ្កាប្រាក់សាមគ្គីដែលផ្តួចផ្តើមដោយ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស និង ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ចំនួន ៨៨,៧៥០ ដុល្លារអាមេរិក និង ៣៣,០៧០,០០០ រៀល ដើម្បីជួសជុលគ្រឹះមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត ជោតិញាណ នាវត្តឧណ្ណាលោម រាជធានីភ្នំពេញ។














## សកម្មភាពមនុស្សធម៌នៅខេត្តឧត្តរមានជ័យដើម្បីយកកាបូប សម្លៀកបំពាក់ រួមជាមួយសម្ភារសិក្សា ដើម្បីចែកដល់សិស្សានុសិស្សចំនួន ២០០នាក់

ក្នុងគោលដៅមនុស្សធម៌ស្របតាមចក្ខុវិស័យនិងបេសកកម្មរបស់ខ្លួនសមាគមឧកញ៉ាកម្ពុជាបាននាំយកនូវកាបូបសម្លៀកបំពាក់រួមជាមួយសម្ភារសិក្សាដើម្បីចែកដល់សិស្សានុសិស្សចំនួន២០០នាក់នៅសាលាបឋមសិក្សាស្រះឈូក ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យកាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៣។










## អ្នកឧកញ៉ា លី យ៉ុងផាត់ រួមជាមួយថ្នាក់ដឹកនាំសមាគមជាច្រើនរូបទៀតនាំយកថវិកា ប្រគល់ជូនដល់កាកបាទក្រហមកម្ពុជាក្នុងឱកាសខួបទី១៦០ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម

នាថ្ងៃពុធ ៥កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយថ្នាក់ដឹកនាំសមាគមជាច្រើនរូបទៀត បាននាំយកថវិកាចំនួន ១,៣៤៣,០០០ដុល្លាអាម៉េរិកដែលទទួលបានពីសប្បុរសជនជាសមាជិក និងសមាជិកានៃសមាគមឧកញ៉ាកម្ពុជាចំនួន ៣៤រូប ប្រគល់ជូនដល់កាកបាទក្រហមកម្ពុជាក្នុងឱកាសខួបទី១៦០ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម។




















## អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាដឹកនាំអ្នកឧកញ៉ា និងឧកញ៉ាជាច្រើនរូបចូលរួម កបិនទានក្រសួងយុត្តិធម៌ក្រោមការផ្តួចផ្តើមរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កើត រិទ្ធ

នៅសុក្រ ៥កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣៖ អ្នកឧកញ៉ាលីយ៉ុងផាត់ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំអ្នកឧកញ៉ានិងឧកញ៉ាជាច្រើនរូបចូលរួមកឋិនទានក្រសួងយុត្តិធម៌ក្រោមការផ្តួចផ្តើមរបស់ឯកឧត្តម កើតរិទ្ធ ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅទីស្តីការក្រសួង ដោយមានថវិកា បាននាំយកនូវបច្ច័យចំនួន ១១,៨០០,០០០រៀល និង ៤១,៧៩៥ដុល្លារអាម៉េរិកដែលជាការចូលរួមចាប់មគ្គផលរបស់អ្នកឧកញ៉ា និងឧកញ៉ាចំនួន ១២៤ រូបជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា។



### ផែនការអនុវត្តបន្ត

- ១.ពង្រឹងកិត្យានុភាពរបស់សមាគមទាំងការផ្សព្វផ្សាយកៀរគរសមាជិកឱ្យបានកាន់តែច្រើនក៏ដូចជាការពារនូវផលប្រយោជន៍ស្របច្បាប់ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់គោរមវន្តដែលជាសមាជិកព្រមទាំងផ្តល់នូវអត្ថប្រយោជន៍នានាស្របទៅតាមការកំណត់នៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សមាគមឧកញ៉ាកម្ពុជា
- ២.បន្តអនុវត្តសកម្មភាពជាដៃគូរាជរដ្ឋាភិបាលលើសកម្មភាពជំរុញពាណិជ្ជកម្ម និងវិនិយោគក្នុងគោលដៅផ្តល់នូវអត្ថប្រយោជន៍ដល់សមាជិកដែលសុទ្ធសឹងតែជាពាណិជ្ជករក៏ដូចជាការរួមចំណែកក្នុងការបង្កើតការងារដល់ប្រជាជនកម្ពុជាផងដែរ
- ៣.សហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជាលើកិច្ចការតំណាងឱ្យគោរមទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាព្រមទាំងការពិនិត្យនិងវាយតម្លៃចំពោះសំណើសុំផ្តល់គោរមងារឧកញ៉ានិងជាពិសេសលើការរៀបចំបច្ចុប្បន្នកម្មបញ្ជីឈ្មោះគោរមវន្តទាំងអស់
- ៤. រៀបចំយន្តការនៃការចូលរួមចំណែកក្នុងសកម្មភាពសង្គម និងសប្បុរសធម៌នានា ដើម្បីបង្កើនកិត្យានុភាព ឧត្តមភាព និងគុណធម៌របស់ឧកញ៉ាឱ្យកាន់តែខ្ពង់ខ្ពស់ថែមទៀត
- ៥. បង្កើតវេទិកា សិក្ខាសាលា និងកម្មវិធីផ្សេងៗទាំងក្នុងនិងក្រៅប្រទេសដើម្បីលើកកម្ពស់ភាពជាដៃគូនៅក្នុងសកម្មភាពពាណិជ្ជកម្ម និងការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ទំនាក់ទំនងនិងទទួលបានព័ត៌មានអំពីយើងខ្ញុំតាមរយៈ

Website Facebook Telegram Youtube TikTok X(Twitter)

## ទំនាក់ទំនងចូលជាសមាជិក

ទីស្នាក់ការ ÷ សណ្ឋាគារភ្នំពេញ លេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក

ខណ្ឌដូនពេញ រាជធានីភ្នំពេញ

លេខទូរសព្ទ ÷ (+855) 23 860 999 ,(+855) 85 202 333 ,(+855) 16 313 777

អ៊ីម៉ែល ÷ info@cambodianoknha.org គេហទំព័រ ÷ www.cambodianoknha.org